# ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥២៦

## ស្តីពី

## សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា

### យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

បង្កើតសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ដែលមានវិសាលភាពទូទាំងប្រទេសកម្ពុជា ហើយដែលធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍ដល់មុខរបរ និងមីក្រូសហគ្រាសក្នុងគោលបំណងជំរុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ជួយបង្កើនធនធានមនុស្ស និងការបង្កើតអាជីពតាមរយៈមុខរបរ និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា ។

សភាមុខរបរ និង មីក្រូសហគ្រាស នៅថ្នាក់ខេត្ត-ក្រុង នឹងត្រូវបង្កើតឡើង ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមសំណើរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

**មាត្រា ២ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា គឺជានីតិបុគ្គលឯកជនមួយ ដែលចងក្រងបង្កើតឡើងដើម្បីបំពេញបេសកកម្ម ដែលមានលក្ខណៈបម្រើផលប្រយោជន៍សាធារណៈ ។

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា គឺជាយន្តការបំពេញបន្ថែមឱ្យសភាពាណិជ្ជកម្មកម្ពុជា ។

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ស្ថិតនៅក្រោមអាណាព្យាបាលជំនាញរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៣ .-**

សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា គឺបណ្តាអាជីវករមុខរបរ និងមីក្រូសហគ្រាសដែលបានចុះឈ្មោះក្នុងបញ្ជីមុខរបរ នៅសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

នីតិវិធីនៃការចុះបញ្ជី ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**មាត្រា ៤ .-**

អាជីវករមុខរបរ និងមីក្រូសហគ្រាស គឺជារូបវ័ន្តបុគ្គល ឬក្រុមគ្រួសារទាំងឡាយណា ដែលប្រកបអាជីវកម្មដូចមាន កំណត់ក្នុងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅទីកន្លែងជាប្រចាំណាមួយ សំដៅសម្រេចឱ្យបាននូវផលិតផលអ្វីមួយ។

អាជីវកម្មមុខរបរ និងមីក្រូសហគ្រាស ដែលមានលក្ខណៈគ្រួសារ គឺអាជីវកម្មដែលគ្មានប្រើប្រាស់កម្មករ ឬប្រើប្រាស់កម្មករ ដោយរាប់បញ្ចូលប្រពន្ធ និងកូន។

**មាត្រា ៥ .-**

បញ្ជីសមាជិកសភាមុខរបរ និងមីក្រូសហគ្រាស គ្រប់គ្រងដោយសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។ អាជីវករមុខរបរ និងមីក្រូសហគ្រាសនីមួយៗ ដូចបានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យនេះ អាចអនុញ្ញាត និងទទួលចុះឈ្មោះក្នុងបញ្ជីសមាជិកភាពនេះបាន លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌចាំបាច់គឺរូបវិន្តបុគ្គល ឬក្រុមហ៊ុន ដែលអាចបញ្ជាក់អំពីសមត្ថភាព ឬ បទពិសោធន៍ យ៉ាងហោចណាស់ ៦ ខែ ។

សមាជិកភាពនេះ តម្រូវឱ្យបង់ភាគទានសមស្របទៅតាមការកំណត់ ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងដោយឡែក និងទទួលសិទ្ធិប្រើប្រាស់សេវាសេវាកម្មរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

**មាត្រា ៦ .-**

សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជាមានតំណាងរបស់ខ្លួន ដែលជ្រើសតាំងតាមរយៈការបោះឆ្នោតនៃមហាសន្និបាត។ ចំនួនអ្នកតំណាងនៃសមាជិកមុខរបរ និងមីក្រូសហគ្រាស នៅក្នុងសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់មហាសន្និបាត ហើយត្រូវបានបែងចែកតាមចង្កោមអាជីវកម្មមុខរបរ និងមីក្រូសហគ្រាសនីមួយៗ ដូចខាងក្រោម ÷

ក- អាជីវកម្មផលិតចំណីអាហារ

ខ- អាជីវកម្មប្រតិស្ឋកម្ម

គ- អាជីវកម្មសំណង់

ឃ- អាជីវកម្មសេវាកម្ម

ង- មុខរបរ និងមីក្រូសហគ្រាសផ្សេងៗទៀត ស្របតាមមាត្រា៧នៃព្រះរាជក្រឹត្យនេះ ។

ចង្កោមអាជីវកម្មមុខរបរ និងមីក្រូសហគ្រាសនីមួយៗ កំណត់នៅក្នុងឧបសម្ព័ន្ធភ្ជាប់។

តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាស គឺជាសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ដែលត្រូវបានជ្រើសតាំងដោយមហាសន្និបាតតំណាងទូទាំងប្រទេស។

**មាត្រា ៧ .-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិអំណាចពង្រីកបន្ថែមនូវអាជីវកម្មមុខរបរ និងមីក្រូសហគ្រាស ដែល កំណត់ពីសកម្មភាពនានា សម្រាប់រាប់បញ្ចូលក្នុងចង្កោមអាជីវកម្មមុខរបរ និងមីក្រូសហគ្រាស។ មុខរបរ និងមីក្រូសហគ្រាស ជាប្រពៃណីជាតិ ទទួលបានការលើកទឹកចិត្តជាអាទិភាព។

មាត្រា ៨ .-

អាជីវករមុខរបរ និងមីក្រូសហគ្រាស ដែលមានមុខរបរដូចគ្នា ឬក៏មានមុខជំនាញប្រហាក់ប្រហែលគ្នា អាចរួមគ្នាបង្កើតជាសមាគមជំនាញមុខរបរ និង មីក្រូសហគ្រាស នៅថ្នាក់មូលដ្ឋានបាន តាមការណែនាំពីសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

មាត្រា ៩ .-

ការបង្កើតសមាគមជំនាញមុខរបរ និងមីក្រូសហគ្រាសនេះ ធ្វើឡើងក្នុងគោលបំណងលើកស្ទួយផលប្រយោជន៍រួម របស់សមាជិកខ្លួន។ សមាគមនេះមានភារកិច្ចសំខាន់ៗ ដូចតទៅ ÷

- ថែរក្សាប្រពៃណីអាជីវកម្ម
- បង្កើនការទាក់ទងល្អរវាងម្ចាស់អាជីវកម្មមុខរបរ និងមីក្រូសហគ្រាស និងសហការីរបស់ខ្លួន
- ជួយដល់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ក្នុងការសម្របសម្រួលដំណើរការបណ្តុះបណ្តាល លើកស្ទួយការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអភិវឌ្ឍន៍ទេពកោសល្យជំនាញ
- ជួយសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

## ជំពូកទី ២

## តួនាទី និងភារកិច្ច របស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា

មាត្រា ១០ .-

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានភារកិច្ចដូចតទៅ ÷

- ជំរុញ និងណែនាំអំពីរបៀបបង្កើតសមាគមជំនាញមុខរបរ និងមីក្រូសហគ្រាស
- ទ្រទ្រង់ផលប្រយោជន៍មុខរបរ និងមីក្រូសហគ្រាស និងបង្កើតយន្តការសមស្របមួយ ដើម្បីជួយគ្នាទៅវិញទៅមករវាងសមាជិកមុខរបរ និងមីក្រូសហគ្រាសនីមួយៗ
- សម្របសម្រួលភាពមិនចុះសម្រុងក្នុងមុខរបរ និងមីក្រូសហគ្រាស រវាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា និង សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ឬរវាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា និង អាជីវករទូទៅ
- ពិគ្រោះជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ចំពោះការប្រតិបត្តិឱ្យមានប្រសិទ្ធភាពនៃនយោបាយសេដ្ឋកិច្ចរបស់ខ្លួន

- គ្រប់គ្រងបញ្ជីសមាជិកមុខរបរ និងមីក្រូសហគ្រាស
- សម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការសុំលិខិតបញ្ជាក់ ឬទទួលស្គាល់គុណភាពស្តង់ដារផលិតផល ឬសេវាកម្មផ្សេងៗ របស់សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា
- ចេញសេចក្តីណែនាំដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្របសម្រួលការបណ្តុះបណ្តាល ឬចេញវិញ្ញាបនប័ត្រដល់សិក្ខាកាម
- រៀបចំ និងលើកសំណើស្តង់ដារបច្ចេកទេស បរិស្ថាន និងសុវត្ថិភាពការងារ ដែលទាក់ទិននឹងជំនាញមុខរបរ និងមីក្រូសហគ្រាស ជូនអាជ្ញាធរមានសមត្ថកិច្ច
- ពិនិត្យលទ្ធភាពក្នុងការពង្រីកសកម្មភាពរបស់ខ្លួន ក្នុងគោលបំណងបម្រើផលប្រយោជន៍ ដូចដែលមានចែងក្នុងមាត្រា ១ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរីកចម្រើន ក្នុងវិស័យមុខរបរ និងមីក្រូសហគ្រាស ។

មាត្រា ១១ .-

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងទិសដៅ ÷

- ជួយណែនាំអាជីវករចូលជាសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា
- ជួយសម្របសម្រួលវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ
- ជួយកំណត់លក្ខណៈសម្គាល់របស់ផលិតផល បច្ចេកវិជ្ជា ធានានូវសុវត្ថិភាពការងារ ជូនដល់អាជីវករ និងកម្មករ និងជួយរួមចំណែកក្នុងកិច្ចការការពារបរិស្ថាន ។

មាត្រា ១២ .-

រៀងរាល់ឆ្នាំ នៅដំណាច់ខែមីនា សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ត្រូវបញ្ជូនរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងផ្សព្វផ្សាយ ។

## ជំពូកទី ៣

## ការបណ្តុះបណ្តាល

មាត្រា ១៣ .-

អាជីវករ និងកម្មករនៃមុខរបរ និងមីក្រូសហគ្រាស ដែលបានចុះបញ្ជីហើយ អាចទទួលបាននូវការសម្របសម្រួល ក្នុងការបណ្តុះបណ្តាលពីសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ។

**មាត្រា ១៤ .-**

ការបណ្តុះបណ្តាលវិជ្ជាជីវៈ គោលដៅលើការផ្តល់ជូនសិក្ខាកាមនូវចំណេះដឹង ចំណេះធ្វើ និងជំនាញចាំបាច់សម្រាប់កិច្ចដំណើរការសកម្មភាពមុខរបរ និងមីក្រូសហគ្រាស ។ ចំណេះដឹង ចំណេះធ្វើ និងជំនាញ សម្រាប់សកម្មភាពមុខរបរ និងមីក្រូសហគ្រាសនីមួយៗ ប្រព្រឹត្តទៅក្រោមកិច្ចសហការជាមួយក្រសួងមានសមត្ថកិច្ចជាជំហានៗ តាមរយៈគម្រោងផែនការបំពាក់បំប៉ន ។

**មាត្រា ១៥ .-**

ការបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើឡើងដោយផ្អែកលើកិច្ចព្រមព្រៀងមួយស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈ រវាងអាជីវករមុខរបរ និងមីក្រូសហគ្រាសដែលបើកការបណ្តុះបណ្តាល និងសិក្ខាកាម ឬតំណាងស្របច្បាប់របស់គេ ។

**មាត្រា ១៦ .-**

ផ្អែកតាមសេចក្តីសម្រេចរបស់មហាសន្និបាត សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានសិទ្ធិរៀបចំកម្មវិធីសិក្សាវិជ្ជាជីវៈបន្ត ។

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានសិទ្ធិយកថ្លៃពីសិក្ខាកាម ដែលតម្លៃនេះនឹងកំណត់ដោយសន្និបាតពេញអង្គ សម្រាប់ផែនការនៃការសិក្សាបន្តខាងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាថ្មី ។

## ជំពូកទី ៤
## ការដឹកនាំ និងការគ្រប់គ្រង

**មាត្រា ១៧ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

- មហាសន្និបាត
- សន្និបាតពេញអង្គ
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការឯកទេស
- លេខាធិការដ្ឋាន ។

## ជំពូកទី ៥
## មហាសន្និបាត

**មាត្រា ១៨ .-**

មហាសន្និបាត គឺជាសម័យប្រជុំរបស់សមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។ តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជានីមួយៗ ត្រូវបានជ្រើសរើសដោយមហាសន្និបាត ដែលមានអាណត្តិ ៥ ឆ្នាំ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មហាសន្និបាត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៩ .-**

តាមសំណើរបស់ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចេញប្រកាសទទួលស្គាល់តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាស ដែលមហាសន្និបាតបានជ្រើសតាំង។

**មាត្រា ២០ .-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចេញប្រកាសទទួលស្គាល់ទីប្រឹក្សារបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា តាមសំណើរបស់ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

## ជំពូកទី ៦
## សន្និបាតពេញអង្គ

**មាត្រា ២១ .-**

ការប្រជុំរបស់តំណាងសមាជិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ហៅថា "សន្និបាតពេញអង្គ ដែលជាអង្គសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា"។ សន្និបាតពេញអង្គ អនុម័តលើសេចក្តីសម្រេចទាំងឡាយ ក្នុងទិសដៅបម្រើ និងការពារ ផលប្រយោជន៍អាជីវករមុខរបរ និងមីក្រូសហគ្រាស ហើយសន្និបាតពេញអង្គនេះអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការចូលរួមពី សមាជិកចំនួន ២ ភាគ ៣ យ៉ាងតិច។

សន្និបាតពេញអង្គ ជ្រើសរើសបន្ថែមនូវអ្នកជំនាញ ៥ រូប យ៉ាងច្រើន ដែលមានវិជ្ជាជីវៈមុខរបរ និងមីក្រូសហគ្រាស តាមចង្កោមអាជីវកម្មនីមួយៗ ជាទីប្រឹក្សា។

**មាត្រា ២២ .-**

សន្និបាតពេញអង្គរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល ដែល មានអាណត្តិ ៥ ឆ្នាំ ។

តាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល សន្និបាតពេញអង្គ បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការឯកទេស ។ គណៈកម្មាធិការឯកទេសនីមួយៗ មានសមាជិកយ៉ាងតិច ៣ នាក់ ។

**មាត្រា ២៣ .-**

សន្និបាតពេញអង្គ សម្រេចការងារដូចខាងក្រោម ÷

១. បោះឆ្នោតជ្រើសតាំងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល

២. បោះឆ្នោតជ្រើសតាំងសមាសភាពរបស់គណៈកម្មាធិការឯកទេស តាមសំណើរបស់ក្រុមប្រឹក្សាភិបាល

៣. អនុម័តគម្រោងថវិកាប្រចាំឆ្នាំ

៤. ផ្តល់សេចក្តីយល់ព្រមលើការទទួលឥណទាន និងជំនួយផ្សេងៗ

៥. ទិញ លក់ ដីធ្លី និងអាគារ

៦. កំណត់នូវភាគទាន សម្រាប់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា និងការយកកម្រៃផ្សេងៗ

៧. ពិនិត្យ និងទទួលយល់ព្រមនូវគណនេយ្យប្រចាំឆ្នាំ

៨. ចេញសេចក្តីណែនាំជាគោលការណ៍ដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ

៩. ធ្វើសេចក្តីសម្រេចលើតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល

១០. ធ្វើវិសោធនកម្មលើបទបញ្ជាផ្ទៃក្នុងរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ។

**មាត្រា ២៤ .-**

សន្និបាតពេញអង្គ ធ្វើឡើងជាសាមញ្ញ ២ ដងក្នុងមួយឆ្នាំ ។ សន្និបាតពេញអង្គវិសាមញ្ញ អាចធ្វើទៅតាមការចាំបាច់ ។ ប្រធានក្រុមប្រឹក្សាភិបាល កោះអញ្ជើញសន្និបាតពេញអង្គនេះជាលាយលក្ខណ៍អក្សរ ក្នុងកំឡុងពេល ២ សប្តាហ៍ មុនពេលបើកសន្និបាត ។ ក្នុងករណីបន្ទាន់ កំឡុងពេលនៃការកោះអញ្ជើញនេះត្រូវបង្រួមមកត្រឹម ៣ ថ្ងៃ ។

របៀបវារៈនៃសន្និបាតពេញអង្គ ត្រូវបានកំណត់នៅក្នុងកម្មវត្ថុនៃសន្និបាតពេញអង្គ ។ ក្នុងករណីចាំបាច់ដែលត្រូវលើកយករបៀបវារៈផ្សេងទៀតមកបន្ថែម ត្រូវមានការយល់ព្រមពីសមាជិកវត្តមាន ២ ភាគ ៣ ។

ការសម្រេចណាមួយក្នុងសន្និបាតពេញអង្គ ចាំបាច់ត្រូវកំណត់ជាកម្មវត្ថុ ឬរបៀបវារៈ ក្នុងសេចក្តីកោះអញ្ជើញ លើកលែងតែកម្មវត្ថុ ឬរបៀបវារៈណាត្រូវបានទទួលការយល់ព្រមពីសមាជិកវត្តមាន ២ ភាគ ៣ ឱ្យដាក់បញ្ចូលបន្ថែមលើរបៀបវារៈក្នុងសន្និបាតពេញអង្គ ។

នីតិវិធីក្រៅពីនេះ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៧

## ក្រុមប្រឹក្សាភិបាល

**មាត្រា ២៥ .-**

ដំណើរការសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល មានប្រធានមួយរូប អនុប្រធានមួយ ឬច្រើនរូប ហិរញ្ញិក អគ្គលេខាធិការ និងសមាជិក ៦ នាក់ ផ្សេងទៀត។

ប្រធាន អនុប្រធាន ហិរញ្ញិក និងអគ្គលេខាធិការ ត្រូវបានបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា ដោយមតិគាំទ្រភាគច្រើននៃសន្និបាតពេញអង្គ។

ប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

ក្រុមប្រឹក្សាភិបាល មានសិទ្ធិជ្រើសរើសទីប្រឹក្សាមួយរូប ឬច្រើនរូប។ អាណត្តិរបស់ទីប្រឹក្សា ស្មើនឹងអាណត្តិរបស់ក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសនាយកប្រតិបត្តិ និងនាយករង ដើម្បីដឹកនាំការងារប្រចាំថ្ងៃ។

ចំពោះមុខនេះ ប្រគល់ភារកិច្ចជូនសម្ព័ន្ធសិប្បកម្មកម្ពុជា ឱ្យទទួលបន្ទុកការងារបណ្ដោះអាសន្នជាលេខាធិការដ្ឋាននៃសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា។

ក្រុមប្រឹក្សាភិបាល ទទួលបន្ទុករៀបចំមហាសន្និបាតនៅដើមអាណត្តិថ្មី និងសន្និបាតពេញអង្គ ហើយនិងអនុវត្តសេចក្ដីសម្រេចរបស់មហាសន្និបាត និងសន្និបាតពេញអង្គ។

**មាត្រា ២៦ .-**

ប្រធានក្រុមប្រឹក្សាភិបាល មានភារៈដឹកនាំកិច្ចប្រជុំរបស់មហាសន្និបាត និងសន្និបាតពេញអង្គ។

ករណីប្រធានមានធុរៈ អនុប្រធានតាមឋានានុក្រមដឹកនាំកិច្ចប្រជុំ។

ប្រធានក្រុមប្រឹក្សាភិបាល ជូនដំណឹង ស្ដីពីកាលបរិច្ឆេទនៃមហាសន្និបាត និងសន្និបាតពេញអង្គ។

តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ៨

## គណៈកម្មាធិការឯកទេស

**មាត្រា ២៧ .-**

គណៈកម្មាធិការឯកទេសរួមមាន :

- គណៈកម្មាធិការសវនកម្ម

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការបណ្តុះបណ្តាលវិជ្ជាជីវៈ និង
- គណៈកម្មាធិការចំពោះកិច្ច ។

**មាត្រា ២៨ .-**

គណៈកម្មាធិការសវនកម្ម ទទួលបន្ទុកត្រួតពិនិត្យលើការដឹកនាំ និងគណនេយ្យភាពរបស់សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជាទាំងមូល ។

**មាត្រា ២៩ .-**

គណៈកម្មាធិការបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបន្ទុកកិច្ចការបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយរៀបចំបញ្ចូលនូវប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈតាមផ្នែកនីមួយៗ ក្នុងកម្មវិធីបណ្តុះបណ្តាលជាតិ ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរ ទទួលបាននូវចំណេះដឹង និងស្ទាត់ជំនាញក្នុងសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៣០ .-**

គណៈកម្មាធិការចំពោះកិច្ច ត្រូវបានចាត់តាំងឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីអនុវត្តការងារដែលមានរយៈពេលខ្លី ។

## ជំពូកទី ៩
## លេខាធិការដ្ឋាន

**មាត្រា ៣១ .-**

លេខាធិការដ្ឋាន ដឹកនាំដោយនាយកប្រតិបត្តិមួយរូប និងនាយករងមួយ ឬច្រើនរូប ដែលទទួលបន្ទុកកិច្ចការរដ្ឋបាល ទំនាក់ទំនង និងហិរញ្ញវត្ថុ ប្រចាំថ្ងៃ ។

**មាត្រា ៣២ .-**

លេខាធិការ មានតួនាទីដូចតទៅ ÷

- ទទួលបន្ទុកលើការរៀបចំបង្កើតសមាគម អាជីវកម្មមុខរបរ និងមីក្រូសហគ្រាស
- ទទួលបន្ទុកលើការផ្សព្វផ្សាយ រកទីផ្សារ និងបណ្តុះបណ្តាលមូលដ្ឋានគ្រឹះរយៈពេលខ្លី
- ទទួលបន្ទុកលើការរៀបចំ និងផ្តល់បច្ចេកវិជ្ជាមុខរបរ និងមីក្រូសហគ្រាស
- ទទួលបន្ទុករាល់ការចេញវិញ្ញាបនប័ត្រដល់សិក្ខាកាម ដែលបានទទួលការបណ្តុះបណ្តាល

- ទទួលបន្ទុកសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីទទួលយកវិញ្ញាបនប័ត្រសម្រាប់ការនាំចេញផលិតផល
- ទទួលបន្ទុករាល់ការរៀបចំ និងលើកសំណើស្តង់ដារបច្ចេកទេស បរិស្ថាន និងសុវត្ថិភាពការងារ ដែលទាក់ទិននឹងជំនាញមុខរបរ និងមីក្រូសហគ្រាស ជូនអាជ្ញាធរមានសមត្ថកិច្ច
- ទទួលបន្ទុកលើការអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកលើការទាក់ទងជាមួយនឹងស្ថាប័នសាធារណៈ
- ទទួលបន្ទុកលើការសម្របសម្រួលគម្រោង
- ទទួលបន្ទុកលើការទាក់ទងជាមួយកម្មវិធីជាដៃគូ
- ទទួលបន្ទុកលើការរៀបចំ និងដឹកនាំកិច្ចប្រជុំរបស់បុគ្គលិកសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា

ទទួលបន្ទុកលើការអនុវត្តការងារផ្សេងៗទៀត ដែលក្រុមប្រឹក្សាភិបាលប្រគល់ជូន ។

## ជំពូកទី ១០

## ហិរញ្ញប្បទាន

**មាត្រា ៣៣ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ប្រមូលភាគទានប្រចាំខែរបស់សមាជិក ក្នុងកម្រិតសមស្របមួយតាមសេចក្តីសម្រេចរបស់សន្និបាតពេញអង្គ ។ សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានសិទ្ធិប្រើប្រាស់ និងចាត់ចែងប្រាក់ភាគទាន សម្រាប់ការចំណាយទៅលើដំណើរការទូទៅ ។

**មាត្រា ៣៤ .-**

សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា មានថវិកា ២ ប្រភេទ ។

ថវិកាប្រភេទ ១ ជាថវិកាដែលប្រើប្រាស់សម្រាប់ការប្រព្រឹត្តទៅរបស់ខ្លួន ។ ប្រភពចំណូលនៃថវិកានេះបានមកពី :

- ភាគទាន និងវិភាជន៍ប្រចាំឆ្នាំរបស់សមាជិក
- ចំណូល និងវិភាគទានមកពីប្រភពផ្សេងៗ
- កម្ចីឥណទានពីធនាគារ និងស្ថាប័នដទៃទៀត

ថវិកាប្រភេទ ២ ជាថវិកាគម្រោងការងារសហប្រតិបត្តិការ ដែលរៀបចំឡើងសម្រាប់មុខរបរ និងមីក្រូសហគ្រាសទាំងឡាយ ដែលខ្លួនគ្រប់គ្រង ។ ប្រភពថវិកានេះ បានមកពីប្រទេស និងស្ថាប័នផ្តល់ជំនួយ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៣៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៦ .-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៧ .-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០០៥

នស/រកត/១២០៥/៥៦៥ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៤៨៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ឧបសម្ព័ន្ធ

## នៃព្រះរាជក្រឹត្យលេខនស/រកត/១២០៥/៥២៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសភាមុខរបរ និង មីក្រូសហគ្រាសកម្ពុជា

ចង្កោមមុខរបរ និងមីក្រូសហគ្រាសដែលជាសមាជិកនៅក្នុងសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជារួមមាន:

ក) មុខរបរ និងមីក្រូសហគ្រាសម្ហូបអាហារ

១. អ្នកដុតនំប៉័ង និងអ្នកធ្វើបង្អែមដំណាប់
២. អ្នកបិតស្រា-កែច្នៃស្រា
៣. អ្នកផលិតទឹកផ្លែឈើ
៤. អ្នកធ្វើនំ និងស្ករគ្រាប់
៥. អ្នកកាប់សត្វ និងអ្នកលក់សាច់
៦. អ្នកផលិតថ្នាំជក់-ការី
៧. កិនស្រូវ និង គ្រាប់ធញ្ញជាតិ
៨. ផ្លែឈើ និង បន្លែ
៩. ស្ករ ស្ករស
១០. ស្រា និងភេសជ្ជៈ

ខ) មុខរបរ និងមីក្រូសហគ្រាសប្រតិស្ឋកម្ម

១. ជាងតុ ទូ
២. ជាងឈើធ្វើទ្វារបង្អួច
៣. ជាងធ្វើទូក និងកាណូត
៤. ជាងក្រឡឹង និងឈូសឈើ
៥. អ្នកក្រងផ្តៅ
៦. ធ្វើខ្សែ ខ្សែពួរ
៧. ជាងឆ្លាក់ថ្ម
៨. អ្នកបោះពុម្ព
៩. ស្មូនកុលាលភាជន៍ ( អ្នកធ្វើក្អម ចាន ឆ្នាំងដី)

១០. អ្នកតម្លើងគ្រឿងភ្លេង

១១. ជាងវិនគា

១២. អ្នកត្បាញ-រវៃ អ្នកធ្វើព្រំ

១៣. សម្លាប់ស្បែក និងផលិតផលអំពីស្បែក

១៤. ជាងចម្លាក់ និងជាងសូនរូប

១៥. ជាងមាស

១៦. ជាងប្រាក់ និងស្ពាន់ (ជាងទង)

១៧. ផលិតផលពីឈើ និងគ្រឿងសង្ហារឹម

១៨. អារឈើ ឈូសឈើ

១៩. បោះពុម្ព និងធ្វើសៀវភៅ

២០. ឧបករណ៍កីឡា

គ) មុខរបរ និងមីក្រូសហគ្រាសសំណង់

១. អ្នករៀបឥដ្ឋ

២. អ្នកដាក់ទ្វារបង្អួច

៣. អ្នកសង់ផ្លូវថ្នល់

៤. អ្នកជីកអណ្តូង

៥. អ្នកយករ៉ែខ្សាច់-គ្រួស និងថ្ម

៦. អ្នកលាបជញ្ជាំង

៧. អ្នកសំណង់លោហៈ

៨. ជាងសំណង់ម៉ាស៊ីន

៩. ជាងផ្សារដែក

១០. ផលិតផលពីដីឥដ្ឋ

១១. ផលិតផលកញ្ចក់ ពិរ

ឃ) មុខរបរ និងមីក្រូសហគ្រាសសេវាកម្ម

១. ជាងកាត់ខោអាវប្រុស-អាវស្រី

២. ជាងស្បែកជើង

៣. ជាងធ្វើកាបូប

៤. ជាងកាត់សក់ស្ត្រី-ប្រុស

៥. អ្នកបោកអ៊ុត

៦. អ្នកថតរូប

៧. ជាងម៉ាស៊ីនត្រជាក់

៨. ជាងការ

៩. ជាងតទឹក

១០. ជាងភ្លើង

១១. ជាងវិទ្យុ និងទូរទស្សន៍

១២. ជាងនាឡិកា

១៣. ជាងឡាន

១៤. ជាងម៉ូតូ

១៥. អ្នកលាបថ្នាំ

ង) មុខរបរ និងមុខក្រសួងហាត្រាសផ្សេងៗទៀត ស្របតាមមាត្រា៧នៃព្រះរាជក្រឹត្យនេះ ។